## II-រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៧៧ អនក្រ_បក

### ស្ដីពីការផ្ទេរឥណទាន

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ។
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៧ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧

-បានឃើញប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែមករា ឆ្នាំ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីចំណាត់ថ្នាក់ចំណូល និងចំណាយថវិកាតាមប្រភេទ ជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤ និងប្រកាសស្តីពីការកែប្រែ និងបំពេញបន្ថែមជាបន្តបន្ទាប់មាន : លេខ ០២២ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ១៩៩៤ លេខ ០០៣ ប្រ.សហវ ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ១៩៩៥ លេខ ៣២៣ ប្រក.សហវ.ថ ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ១៩៩៥, លេខ ៣៣៦ ប្រក.សហវ.ថ ចុះថ្ងៃទី ១២ ខែតុលា ឆ្នាំ១៩៩៥ លេខ ០៧១ ប្រក.សហវ.ថ ចុះថ្ងៃទី ០៥ ខែមេសា ឆ្នាំ១៩៩៦ និងលេខ ៨០១ សហវ.ថ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ ១៩៩៦

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា១.**- ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានពីជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) ចំនួន ៧២០ លានរៀល (ប្រាំពីររយម្ភៃលានរៀលគត់) មកជំពូក ១០ (បៀវត្ស និងប្រាក់បំណាច់) ក្នុងវង្វង់ថវិការបស់ក្រសួងសុខាភិបាល សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ។

**មាត្រា២.**- ឥណទានក្នុងមាត្រា១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ ដើម្បីផ្តល់ជូនក្រសួងសុខាភិបាល សំរាប់បើកប្រាក់ម៉ោងបន្ថែមជូនសាស្ត្រាចារ្យ បង្រៀននៅមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រ និងសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រក្នុងឆ្នាំ ១៩៩៧ ។

**មាត្រា៣**.-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

**អ៊ុង ហួត ហ៊ុន សែន**